**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# សុន្ទរកថាបិទ

## របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស
## ក្នុងឱកាសសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី
## "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល"
## ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា

*************

សូមគោរព

- ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!

សន្និសីទរបស់យើងបានឈានមកដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា សន្និសីទនេះបានប្រព្រឹត្តទៅប្រកបដោយជោគជ័យនិងផ្លែផ្កា ។ តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏សកម្មរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍លើប្រធានបទរបស់សន្និសីទយើងនៅពេលនេះ ។

ដូចដែល លោកជំទាវ ទេសាភិបាលរង វាគ្មិន ក៏ដូចជា ឯកឧត្តម លោកជំទាវ លោក លោកស្រី បានលើកឡើង ដុល្លារូបនីយកម្មគឺជាបញ្ហាប្រឈមដ៏ចម្បងមួយចំពោះសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរយើងទូទាំងប្រទេស ។ ដុល្លារូបនីយ-កម្មបានដាក់កំហិតលើប្រសិទ្ធភាពនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក្នុងការគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ច ដូចជា គោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ ក្នុងការរក្សាស្ថិរភាពថ្លៃ និងជំរុញពាណិជ្ជកម្ម ការខាតបង់ប្រាក់ចំណូលពីការបោះពុម្ពប្រាក់រៀល និងការបាត់បង់ឱកាសនានាទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ប្រាក់រៀល រួមមានការកាត់បន្ថយចំណាយប្រតិបត្តិការនិងហានិភ័យអត្រាប្តូរប្រាក់ ជាដើម ។

អង្គសន្និសីទ បានទទួលស្គាល់ពីសារៈសំខាន់នៃតួនាទីរបស់ប្រាក់រៀល ក្នុងការគាំទ្រនិងជំរុញកំណើននិងភាពធនមាំរបស់សេដ្ឋកិច្ចកម្ពុជា ។ ប្រាក់រៀលតំណាងឱ្យអធិបតេយ្យភាពផ្នែកនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងរូបិយវត្ថុជាតិ ។ ការប្រើប្រាស់ប្រាក់រៀលនឹងរួម



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ចំណែកពង្រឹងអត្តសញ្ញាណនិងសាមគ្គីជាតិ លើកកម្ពស់ការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គាំទ្រការវិនិយោគនិងបង្កើតការងារ គរពូនទុនបម្រុងអន្តរជាតិ និងជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ។ល។ បញ្ហាដុល្លារូបនីយកម្មគឺជាបញ្ហាម៉ាក្រូ ដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងវិស័យសាធារណៈ និងឯកជន ចូលរួមក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល រាប់តាំងពីការប្រើប្រាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ រហូតដល់ការសន្សំនិងការវិនិយោគធំៗ ។ កិច្ចពិភាក្សាក៏បានសង្កត់ធ្ងន់ថា ការអភិវឌ្ឍទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ គឺជាបុរេលក្ខខ័ណ្ឌចម្បងក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល ផ្អែកលើយន្តការទីផ្សារ ។ ទីផ្សារទាំងនេះរួមមាន ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ និងទីផ្សារមូលបត្រ ។ ទន្ទឹមនេះ ការបង្កើតការធានារ៉ាប់រងលើប្រាក់បញ្ញើជាប្រាក់រៀល នឹងបង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រាក់រៀលក្នុងការសន្សំ និងវិនិយោគ ឱ្យកាន់តែទូលំទូលាយ នៅក្នុងសេដ្ឋកិច្ច ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សន្និសីទរបស់យើងនាថ្ងៃនេះ បានរួមចំណែកពង្រឹងការស្រាវជ្រាវនិងការយល់ដឹងទៅលើសារៈសំខាន់នៃប្រាក់រៀល និងតួនាទីរបស់ទីផ្សារហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល នៅក្នុងសេដ្ឋកិច្ចកម្ពុជា ។ ខ្ញុំក៏សង្ឃឹមថា លទ្ធផលនៃកិច្ចពិភាក្សារបស់យើង គឺជាធាតុចូលសម្រាប់អ្នករៀបចំគោលនយោបាយនិងតួអង្គសំខាន់ៗនៅក្នុងវិស័យហិរញ្ញវត្ថុ ក្នុងការពង្រឹងការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយប្រកបដោយនិរន្តរភាព ។ លើសពីនេះ កិច្ចពិភាក្សានឹងអាចនាំទៅរកការស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធសំខាន់ៗបន្ថែមទៀតនាពេលអនាគត ។ ដូចនេះ ខ្ញុំសូមលើកទឹកចិត្តដល់សេដ្ឋវិទូនិងអ្នកស្រាវជ្រាវនានាបង្កើនការស្រាវជ្រាវលើប្រធានបទនេះ ឲ្យកាន់តែស៊ីជម្រៅថែមទៀត សំដៅរកឃើញនូវអនុសាសន៍ល្អៗ ដែលមានប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ។ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងមានជ័យជំនះគ្រប់ភារកិច្ច ។

**សូមអរគុណ!**